ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ
ក្រុមការងាររបស់ គ.ជ.វ.វ
លេខ ....០០១៥៥..../ គ.ជ.ទ.ទ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារដឹកនាំការពិគ្រោះយោបល់ជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

**យោង** :

-ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៩៥ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ) ។

-អនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៦ ស្តីពីការបង្កើតក្រុមការងាររបស់ គ.ជ.វ.វ ។

## សម្រេច

**ប្រការ ១.**

បង្កើតក្រុមការងារ ដឹកនាំការពិគ្រោះយោបល់ជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ដើម្បីបន្តនិរន្តរភាពការងារពីកម្មវិធីសិលា ដែលមានសមាសភាពដូចខាងក្រោម ÷

១. ឯកឧត្តម **សក់ សេដ្ឋា** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន
២. ឯកឧត្តម **លេខ ទី** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន
៣.ឯកឧត្តម **ឡាយ ណារុធ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ
៤. លោក **យិន ម៉ាលីណា** អនុប្រធាន នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ
៥.លោក **ទន ស៊ីផា** ប្រធានការិយាល័យ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ
៦.លោក **ស៊ី ទរិន** ប្រធានការិយាល័យ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ
៧.លោក **នី គីមសាន** ប្រធានការិយាល័យ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ
៨.លោក **នួន ពុទ្ធារ៉ា** មន្ត្រី នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ
៩.លោក **ទេព តារុន** ជំនួយការឯកឧត្តមព្រុំ សុខា ។

**ប្រការ ២.**

ក្រុមការងារនេះមានតួនាទីភារកិច្ច ÷

- ជួបពិភាក្សាជាមួយថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធ របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ដើម្បីរៀបចំកម្មវិធីការងារអនុវត្តជាក់ស្តែង សម្រាប់ការផ្ទេរការងារពីកម្មវិធីសិលាមក គ.ជ.វ.វ ដើម្បីបន្តដឹកនាំអនុវត្ត ។

- ពិភាក្សា និងសិក្សាស្វែងយល់ អំពីរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា រួមមានប្រព័ន្ធគ្រប់គ្រងការងារហិរញ្ញវត្ថុ ការងារគ្រប់គ្រងកិច្ចសន្យា ការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការងារគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ កិច្ចសម្របសម្រួលគម្រោងគ្រប់គ្រងធនធានធម្មជាតិ ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា ។

- កំណត់មុខងារ តួនាទី និងភារកិច្ចចាំបាច់នានា របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ដែលនឹងត្រូវផ្ទេរមក គ.ជ.វ.វ ។

- រៀបចំយន្តការនៃការផ្ទេរប្រព័ន្ធការងារ មន្ត្រីបច្ចេកទេស ឧបករណ៍សម្ភារៈនានានៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា មកក្រោមការទទួលខុសត្រូវរបស់ គ.ជ.វ.វ ។

- រៀបចំរបាយការណ៍ និងផ្តល់អនុសាសន៍ជូនក្រុមការងាររបស់ គ.ជ.វ.វ ពីយន្តការ និងនីតិវិធីនៃការផ្ទេរប្រព័ន្ធការងារ មុខងារ មន្ត្រីបច្ចេកទេស និងឧបករណ៍សម្ភារៈពីអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា មកក្រោមការទទួលខុសត្រូវរបស់ គ.ជ.វ.វ ។

-អនុវត្តភារកិច្ចបន្ថែមទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមការងារ របស់គ.ជ.វ.វ ។

**ប្រការ ៣.**

អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ សាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវសហការ និងទទួលអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៤.**

សេចក្តីសម្រេចនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៩...ខែ...ឆ្នាំ ២០០៦

**រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ**

**និងជាប្រធានក្រុមការងារ គ.ជ.វ.វ**

ព្រុំ សុខា

<u>ចម្លងជូន</u>

-ក្រសួង ស្ថាប័ន សមាជិក គ.ជ.វ.វ

"ជូនជ្រាប"

-អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ

ដឹកនាំការងារនៃកម្មវិធីសិលា

"សហការអនុវត្ត"

-ដូចប្រការ ១ "អនុវត្ត"

-ឯកសារ-កាលប្បវត្តិ

៤៩